# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Mar-2016, 15:31
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ **សាធារណៈ (កោសលុប)**

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ

ហត្ថលេខា:

---

**សំណើរបស់ នួន ជា អនុលោមតាមវិធាន៨៧(៤)សុំកោះហៅសាក្សីបន្ថែម និងសំណើអនុលោមតាមវិធាន៩៣ សុំបំពេញកិច្ចស៊ើបសួរបន្ថែម ទាក់ទងនឹងវគ្គសវនាការនៅក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងមន្ទីរសន្តិសុខ ស២១ និងការបោសសម្អាតផ្ទៃក្នុង**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

ព្រុំ ផល្លា

Doreen CHEN

Xiaoyang NIE

**ចម្លងជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**សហព្រះរាជអាជ្ញា÷**

ជា លាង

Marina HAKKOU
Léa KULINOWSKI

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៨៧(៤) និង៩៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហមេធាវីការពារក្តី លោក នួន ជា (“មេធាវីការពារក្តី”) សូមដាក់សំណើនេះ ព្រមជាមួយសំណើស្រដៀងនេះដែលនឹងដាក់ជាបន្តបន្ទាប់ សុំស្តាប់សក្ខីកម្មសាក្សីប្រាំមួយនាក់បន្ថែមទៀតសម្រាប់វគ្គសវនាការក្នុងសំណុំរឿង០០២/០២ ទាក់ទងនឹងមន្ទីរសន្តិសុខស២១ (“វគ្គសវនាការទាក់ទងនឹងមន្ទីរសន្តិសុខស២១”) ដែលជាផ្នែកនៃវគ្គសវនាការទាក់ទងនឹងមន្ទីរសន្តិសុខ និងការបោសសំអាតផ្ទៃក្នុង (“វគ្គសវនាការទាក់ទងនឹងការបោសសំអាតផ្ទៃក្នុង”) និងសំណើសុំបើកកិច្ចស៊ើបសួរបន្ថែមជាប់ទាក់ទងជាមួយវគ្គសវនាការនេះ ។

## II. ប្រវត្តិសាវតារ

២. នៅថ្ងៃទី ០៨ និងថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៤ មេធាវីការពារក្តី និងភាគីនានាបានដាក់រៀងៗគ្នានូវបញ្ជីបច្ចុប្បន្នភាពស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើសុំសម្រាប់សំណុំរឿង ០០២/០២[1]។

៣. នៅថ្ងៃទី១៥, ១៦, ១៧, ២២ និង ២៣ ខែមិថុនា ឆ្នាំ២០១៥ សាក្សី កែវ លឿ និង សែម ហឿន បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអំពីការជាប់ទាក់ទងផ្ទាល់របស់ពួកគេនៅក្នុងការការបះបោរ និងការប៉ុនប៉ងធ្វើរដ្ឋប្រហារមួយដែលដឹកនាំដោយ ស្បូយ ហ៊ីម ហៅ អឿន មេបញ្ជាការកងពលលេខ៣១០ នៃកងទ័ពបដិវត្តន៍កម្ពុជា ប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងការចាប់ខ្លួនជាបន្តបន្ទាប់លើឈ្មោះ អឿន និងជន

[1] ឯកសារ **E305/4** បញ្ជីឈ្មោះ និងព័ត៌មានសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើសុំចុះថ្ងៃទី០៨ ខែ ឧសភា ឆ្នាំ ២០១៤។ ឯកសារ **E305/5** “សាក្សី និងអ្នកជំនាញស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២” ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤។ ឯកសារ **E305/6** (បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសេចក្តីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿងលេខ ០០២/០២ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន ៥៖ I, II, IIក, III និង IIIក) ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤។ ឯកសារ **E305/7** “បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង សម្រាប់សំណុំរឿង ០០២/០២ ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់” ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤។

សង្ស័យដទៃទៀតដែលជាប់ពាក់ព័ន្ធជាមួយការបះបោរ និងរដ្ឋប្រហារនេះ[2] ។ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ មេធាវីការពារក្តីបានប្រកាសនៅក្នុងតុលាការថា ក្នុងអំឡុងពេលវគ្គសវនាការទាក់ទងនឹង "ការបោសសំអាតផ្ទៃក្នុងមេធាវីការពារក្តីអាចស្នើសុំស្តាប់សក្ខីកម្មសាក្សីពីររូបបន្ថែមទៀត- [redacted] (សាក្សី ក) និង [redacted] (សាក្សី ខ) ដែលបានចូលរួមការបះបោរ និង ការប៉ុនប៉ងធ្វើរដ្ឋប្រហារជាមួយ អឿន ដែរ[3]។

៤. នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះមនុស្ស៩នាក់ដែលត្រូវចូលខ្លួនជាសាក្សី ឬជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងមន្ទីរសន្តិសុខស២១[4]។ ផ្អែកលើកាលវិភាគបច្ចុប្បន្ន បុគ្គលដំបូងគេនៅក្នុងបញ្ជីនេះត្រូវគេរំពឹងថានឹងចូលខ្លួននៅដំណាច់ខែមីនា ឆ្នាំ ២០១៦នេះ ។

## III. ច្បាប់ជាធរមាន

៥. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យអង្គជំនុះជម្រះកោះហៅជនណាម្នាក់ជាសាក្សី ដែល "[អង្គជំនុះជម្រះចាត់ទុកថា] មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភាគី ។ វិធាននេះតម្រូវឲ្យអង្គជំនុះជម្រះពិចារណាខ្លឹមសារនៃសំណើនោះតាមលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន៨៧(៣) នៃផ្ទៃក្នុង។ សម្រាប់ភាគីដែលស្នើសុំវិញ ភាគីនោះត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្មនោះមិនអាចទទួលបានទេនៅពេលបើកសវនាការ[5]។ អង្គជំនុំជម្រះបានយល់ឃើញថានៅក្នុងករណីដែលភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់បុគ្គលម្នាក់ ត្រូវបានបង្ហាញដោយព័ត៌មានតិចតួចបំផុតនៅមុនបើកសវនាការ ខណៈដែលព័ត៌មានលម្អិតច្រើនទៀតទើបតែអាចរកបាននៅក្រោយបើក

---

[2] សូមមើលឧទាហរណ៍ប្រតិចារិតសវនាការថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩១៥ (កែវ លី E1/316.1 នៅទំព័រ 7-8, 33-38; ប្រតិចារិតសវនាការថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩១៥ (កែវ លួ E1/317.1 នៅទំព័រ 10-12 ។ ប្រតិចារិតសវនាការថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩១៥ (សែម ហួន ស E1/319.1) នៅទំព័រ 76-85.

[3] សូមមើលប្រតិចារិតសវនាការថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩១៥ (ហ៊ឹម ហាន E1/321.1) នៅទំព័រ ១០ ។

[4] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់បញ្ជូនមកភាគីចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៦។

[5] អង្គជំនុំជម្រះបញ្ជាក់ថា ការបើកសវនាការនៅក្នុងសំណុំរឿង ០០២ គឺជាសនាការបឋម ដែលបានចាប់ផ្តើមនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១។

សវនាការ នោះសក្ខីកម្មរបស់បុគ្គលនេះ នឹងត្រូវចាត់ទុកថាមិនអាចរកបាននៅមុនបើកសវនាការ[6]។ ក្នុងករណីដែលសក្ខីកម្មអាចទទួលបាននៅមុនពេលបើកសវនាការ អង្គជំនុំជម្រះបានសម្រេចថា "ដរាបណាមានតម្រូវពីផលប្រយោជន៍នៃយុត្តិធម៌ ជាពិសេសដរាបណាភ័ស្តុតាងទាំងនេះជាភ័ស្តុតាងដោះបន្ទុក ដែលតម្រូវឱ្យធ្វើការវាយតម្លៃដើម្បីជៀសវាងការសម្រេចសេចក្តីដោយអយុត្តិធម៌"[7] ឬក្នុងករណីដែល "ទាក់ទងជិតស្និទ្ធទៅនឹងឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង ... ផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យវាយតម្លៃប្រភពទាំងនេះរួមគ្នា"[8] ដើម្បីឆ្លើយតបទៅនឹងវិធាន ៨៧(៣) ភស្តុតាងដាក់នៅចំពោះមុខអង្គជំនុំជម្រះត្រូវការតែភាពពាក់ព័ន្ធ *បឋម* និងភាពជឿទុកចិត្តបាន[9]។

៦. វិធាន៩៣នៃវិធានផ្ទៃក្នុង ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា"។

## IV. **ឧឡារិករណ៍**

### ក. **សាក្សីថ្មី**

*i)* [redacted] *(សាក្សី ក)*

[6] ប្រតិចារិតសវនាការថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ (សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង **E1/363.1**, នៅទំព័រ៤៩ ln. 16 ។

[7]**E307/1** "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3) ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៤ កថាខណ្ឌ ៣។ ឯកសារ E190 "សេចក្តីសម្រេចលើឯកសារថ្មី និងបញ្ហាផ្សេងៗ" ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ៣៦។

[8]**E289/2** "សេចក្តីសម្រេចលើសំណើតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងនៅចំពោះមុខអង្គជំនុមជម្រះ (E289) និងចម្លើយតបរបស់ ខៀវ សំផន (E289/1)" ថ្ងៃទី១៤ មិថុនា ឆ្នាំ២០១៣ កថាខណ្ឌ៣។ **E190** សេចក្តីសម្រេចលើភស្តុតាងថ្មី នៅកថាខណ្ឌ៣៦ ។

[9] ឯកសារ **E313** "សាលក្រម សំណុំរឿង ០០២/០១"ថ្ងៃទី៧ សីហា ឆ្នាំ២០១៤ កថាខណ្ឌ ២៦។

៧. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ [redacted] (សាក្សីក) ជាកងទ័ពក្នុងកងពលលេខ១ (ក្រោយមកកងពលលេខ៣១០) ដែលមានមេបញ្ជា អួន (អាចសរសេរ "អឿន")[10]។ នៅពេលសួរអំពីសកម្មភាព អឿន [redacted] (សាក្សីក) លើកឡើងថា:

> នៅពេលនោះ គាត់មានទំនាក់ទំនងជាមួយ យួន ដែលចង់បះបោរនៅក្នុងទីក្រុងភ្នំពេញ [...] គាត់រៀបចំផែនការវាយប្រហារ ។ [...] ជាដំបូងគាត់ហៅពួកយើងមកប្រជុំសម្ងាត់ ហើយបានណែនាំយើងខ្ញុំថា គាត់មានផែនការវាយប្រហារទីក្រុងភ្នំពេញ។ គាត់ប្រាប់ពីការរំដោះ និងត្រួតត្រាទីក្រុងភ្នំពេញ [...] ។ គាត់និយាយថា សង្គមឥឡូវមិនល្អ ។ [...] ទ័ពចំនួន១០០នាក់ រួមទាំងរូបខ្ញុំដែរ ត្រូវបានឲ្យទៅចូលរួមប្រជុំនោះ ។ ខ្ញុំដឹកអាវុធមួយឡានពេញទៅឲ្យគាត់នៅភ្នំពេញដើម្បីរៀបចំការវាយប្រហារទីក្រុងភ្នំពេញ ។ ជាអកុសលផែនការរដ្ឋប្រហារត្រូវបានបែកការណ៍ [...] ។ កំលាំងវាយសម្រុក និងកំលាំងទប់ស្កាត់ ។ យើងទទួលបានគ្រាប់រំសេវពីបរទេស[11]។

៨. [redacted] (សាក្សីក) និយាយថា ពួកគេឈរជើងនៅតំបន់ទួលគោក ដើម្បីរៀបចំការវាយប្រហារប៉ុល ពត ។ នៅពេលផែនការក្បត់ត្រូវបានបែកការណ៍ ពួកគេទៅធ្វើស្រែនៅ កប់ស្រូវ "ដើម្បីបំភាន់ការតាមដាន" ហើយពួកគេនឹងបញ្ជូនមកវិញនៅពេលណា "មានសុវត្ថិភាព"[12]។

៩. នៅពេលសួរ តើគាត់ជឿថាពួកគេអាចវាយឲ្យបរាជ័យប៉ុលពតដែរទេ [redacted] (សាក្សីក) និយាយថា:

> វាមិនងាយដូចអញ្ចឹងទេ ខ្ញុំទាយ ។ ប្រសិនបើយើងមិនអាចយកឈ្នះលើប៉ុលពត យើងនឹងទៅពឹងវៀតណាម និងសុំកំលាំងពីបូព៌ារបស់ចង្រ្កឹមកជួយ ។ [...] ជាដំបូងពួកគេរៀបចំផែនការវាយប្រហារពីខាងក្នុង។ នៅពេលផែនការវាយប្រហារត្រូវបានបែកការណ៍ ពួកគេមានផែនការសុំជំនួយពីយួន[13] ។

---

[10] **E3/7535**, "ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០៥ ("ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា") ERN 00324166 ។

[11] **E3/7535** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00324168 ។

[12] **E3/7535** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00324173 ។

[13] **E3/7535** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00324172 ។

១០. [redacted] (សាក្សី ក) ធ្លាប់ជាផ្នែកនៃកំលាំងដែលមានភារកិច្ចទទួលភ្ញៀវបរទេសនៅទីក្រុងភ្នំពេញ ។ គាត់បាននិយាយថា ក្នុងចំណោមភ្ញៀវបរទេសដទៃទៀត "ភ្ញៀវវៀតណាមក៏មកទស្សនាដែរ រហូតដល់ផែនការក្បត់ត្រូវបានបែកការណ៍។ បន្ទាប់មកពួកយើងចាប់ផ្តើមបង្កើតបញ្ហាជាមួយវៀតណាម"[14] ។

១១. ក្រោយមកនៅក្នុងឆ្នាំ១៩៧៨ [redacted] (សាក្សី ក) ជាមួយទ័ពពីភូមិភាគនិរតី បានចូលរួមបង្ក្រាបការបះបោររបស់ទ័ពនៅភូមិភាគបូព៌ា ដែលដឹកនាំដោយ សោ ភឹម[15] ។

*ii)* *សាក្សី* [redacted] *(សាក្សី ខ)*

១២. សាក្សី [redacted] (សាក្សី ខ) ចូលរួមកងពលធំលេខ១របស់ភូមិភាគឧត្តរ ដែលដឹកនាំបញ្ជាដោយ អឿន នៅក្នុងឆ្នាំ១៩៧៤ និងបានដឹកនាំបញ្ជាកងអនុសេនាធំមួយ[16] ។ នៅពេលសួរអំពីការចាប់ខ្លួន អឿន សាក្សី [redacted] (សាក្សី ខ) ថ្លែងឡើងថា:

> ខ្ញុំបានដឹងអំពីរឿងនេះដែរនៅពេលចាប់ខ្លួននោះ តែយើងមិនបានដឹងនឹងត្រូវធ្វើអី ពិព្រោះយើងនៅឆ្ងាញពីគ្នាពេក។ ប្រសិនបើយើងនៅជិតគាត់ យើងប្រហែលជា... [...]។ នៅចុងឆ្នាំ១៩៧៦ យើងហៀបនឹងផ្ទុះ តែត្រូវបានបែកការណ៍ ។ កងទ័ពពីរកងពលរបស់ភូមិភាគឧត្តរបានត្រៀមលក្ខណៈប្រយុទ្ធរួចជាស្រេចចេញពីខាងជើងភ្នំ ។ ភូមិភាគបូព៌ាដែលទទួលបន្ទុកទិសទក្សិណ ក៏ត្រៀមលក្ខណៈប្រយុទ្ធជាស្រេចដែរ តែត្រូវបានបែកការណ៍ ហើយ [កុយ ធួន] ប្រធានភូមិភាគឧត្តរ ត្រូវបានចាប់ខ្លួន[17]។

១៣. នៅពេលសួរ តើពិតជាមានផែនការបះបោរដោយ សោ ភឹម ហ្វូ នឹម និង ហ្វូ យុន ដែរ [redacted] (សាក្សី ខ) និយាយថា:

---

[14] **E3/7535** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00324170 ។

[15] **E3/7535** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00324183-84

[16]**E3/7540** "ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ ("ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា") ERN 00337710-11

[17] **E3/7540** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00337712

បាទ មាន។ ពួកគេរៀបចំប្រយុទ្ធនៅឆ្នាំ១៩៧៦ តែយើងមិនដឹងអង្គការជានរណា ឬ អ្នកណាជាសត្រូវរបស់យើង ។ ពួកគេមានកងទ័ពរៀបចំការវាយប្រហារដោយកាំភ្លើងធ្លោង និងអាវុធដៃ តែត្រូវបានបែកការណ៍[18]។

១៤. បន្ទាប់ពីផែនការក្បត់ត្រូវបានបែកការណ៍ប្ដីរបស់ [redacted] (សាក្សី ខ) ដែលជាមេបញ្ជាការរងកងវរៈសេនាតូចមួយនៅក្នុងកងពល១៣០ ត្រូវបានចាប់ខ្លួន និងបញ្ជូនមក "ទួលស្លែង" ភ្លាម[19]។ ម្យ៉ាងវិញទៀត [redacted] (សាក្សី ខ) ត្រូវបានបញ្ជូនមកព្រៃសនៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩៧៧ ដែលនៅទីនោះគាត់ និងទាហានផ្សេងទៀត ត្រូវបានគេប្រាប់ថាជាជនក្បត់ដែលបានក្បត់ និងចូលរួមជាមួយយួន[20] ។

*iii)* [redacted] *(សាក្សី គ)*

១៥. [redacted] (សាក្សី គ) ជាទ័ពនៅក្នុងកងពល៣១០ ដែលស្ថិតនៅក្រោមបញ្ជាការ អឿន[21]។ ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ [redacted] (សាក្សី គ) ធ្លាប់បញ្ជូនឯកសារ និងលិខិតរវាងកប់ស្រូវ និងទីបញ្ជាការកងពលនៅទីក្រុងភ្នំពេញ[22]។ អនុលោមតាមឯកសារមួយដែលគាត់អានជាសម្ងាត់ "មានផែនការដែលក្នុងនោះសហរដ្ឋអាមេរិកនឹងចូលមកជួយក្នុងរយៈពេល២៤ម៉ោង"[23] ។ [redacted] (សាក្សី គ) ថ្លែងបន្ថែមទៀតថា:

> បើតាមឯកសារដែលខ្ញុំអានជាសម្ងាត់ ពួកគេមានផែនការកែប្រែប្រទេសកម្ពុជាឲ្យទៅជាលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។ ពួកគេមានផែនការបំផ្លិចបំផ្លាញ ប៉ុល ពត និងបង្កើតច្បាប់ថ្មី តែបន្ទាប់ពីកម្មាភិបាលជាន់ខ្ពស់ត្រូវបានចាប់ខ្លួន កម្មាភិបាលថ្នាក់ទាបដែលបានចូលរួមនៅក្នុងការរៀបចំសកម្មភាពក្បត់ បានរំសាយវិញ។ [...] បណ្ដាញត្រូវបានកាត់ផ្ដាច់ ។ ប្រសិន

---

[18] **E3/7540** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00337713

[19] **E3/7540** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00337713-14

[20] **E3/7540** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00337715, 00337717

[21] **E3/7523** "ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥("ការសម្ភាសន៍ [redacted] អំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា") ERN 00875544-46, 00875553

[22] **E3/7523** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00875570

[23] **E3/7523** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00875575

បើផែនការក្បត់ត្រូវបានអនុវត្តដោយជោគជ័យ ពួកគេទាំងអស់នឹងនៅរស់។ បើតាមឯកសារដែលខ្ញុំអាន អ្នកដែលបានចូលរួមក្នុងការរៀបចំផែនការក្បត់ រួមមាន តាសុខ នៅភូមិភាគនិរតី តាសោភឹម និងអ្នកតស៊ូចាស់ជាច្រើននាក់ទៀត[24] ។

១៦. នៅពេលសួរ តើសោភឹម បានចូលរួមនៅក្នុងផែនការក្បត់ជាមួយ កុយ ធួន [redacted] (សាក្សី គ) បានឆ្លើយថា "បាទ" ។ បើតាមផែនការក្បត់ ពួកគេបានរៀបចំកសាងសង្គមថ្មីមួយ"[25] ។

*iv) សាក្សី [redacted] (សាក្សី ឃ)*

១៧. សាក្សី [redacted] (សាក្សី ឃ) ជាទ័ពនៅក្នុងកងពលតូចលេខ១ ដែលដឹកនាំបញ្ជាដោយ អឿន[26]។ គាត់និយាយថា អឿន "បានសហការជាមួយពួក ធុច (Thuch)" ហើយបានបន្ថែមថា:

> ពួកគេរៀបចំការបះបោរ ។ ខ្ញុំបានឃើញមនុស្សមួយចំនួនកាន់អាវុធធំ និងអាវុធដៃ។ តែក្រោយមកពួកគេចាប់ខ្លួនសមាជិករបស់ពួកធុចនៅក្នុងកងវរៈសេនាតូច និងកងវរៈសេនាធំ[27]។

១៨. សាក្សី [redacted] (សាក្សី ឃ) និយាយថា "ធុចស្ថិតនៅទីតាំងផ្សេង។ គាត់នឹងបះបោរ តែមិនបានធ្វើទៅវិញ" ពួកនិរតីចាប់ខ្លួនក្រុមរបស់គាត់"[28]។ [redacted] (សាក្សី ឃ) ត្រូវបានបំពាក់អាវុធ តែមិនបានវាយប្រយុទ្ធទេ ដោយសារការចាប់ខ្លួនកើតឡើងនៅដំណាច់ឆ្នាំ ១៩៧៦[29] ។

*v) [redacted] (សាក្សី ង)*

---

[24] **E3/7523** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00875575-76

[25] **E3/7523** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00875576

[26] **E3/5686** "ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី១៨ ខែ មករា ឆ្នាំ២០១៥ ("ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា") ERN 00874668

[27] **E3/5686** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00874669

[28] **E3/5686** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00874669

[29] **E3/5686** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00874669-70

១៩. [redacted] (សាក្សី ង) ជាមេបញ្ជាការកងអនុសេនាធំមួយរបស់កងពល១៣០[30]។ [redacted] (សាក្សី ង) លើកឡើងថា:

> បើតាមអ្វីដែលខ្ញុំបានឮ កុយ ធួន ត្រូវបានចាប់ខ្លួនយូរមកហើយ ពិព្រោះគាត់មានទំនាក់ទំនងខាងផ្លូវភេទ ។ ខ្ញុំមិនបានដឹងច្រើនអំពីរឿងរ៉ាវនេះទេ ។ ខ្ញុំបានឮអំពីរឿងហ្នឹងពីមនុស្សផ្សេង។ ដំបូងគាត់មានទំនាក់ទំនងផ្លូវភេទ ។ ទីពីសាវតាររបស់គាត់ត្រូវបានរកឃើញ អញ្ចឹងទើបគេចាប់គាត់[31] ។

២០. នៅឆ្នាំ១៩៧៧ នៅមុនការចាប់ខ្លួន អឿន និងកម្មាភិបាលផ្សេងទៀតពីកងពល១៣០ [redacted] (សាក្សី ង) បានឮពីក្នុងកិច្ចប្រជុំមួយដែលរៀបចំឡើងដោយមេបញ្ជាកងវរៈសេនាធំរបស់គាត់ឈ្មោះ សុង[32] ។ [redacted] (សាក្សី ង) និយាយថា:

> នៅថ្ងៃមួយនៅពេលធ្វើការនៅបឹងប្រយាប ខ្ញុំកំពង់អង្គុយនៅជាន់ផ្ទាល់ដី ហើយមានការប្រជុំ CIA មួយនៅផ្ទះ ។ នៅពេលនោះខ្ញុំទើបតែត្រឡប់ពីធ្វើការវិញ ដូច្នេះខ្ញុំមិនបានចូលរួមជាមួយពួកគេទេ ។ ខ្ញុំឮពួកគេនិយាយ "កុំរំភើបខ្លាំងពេកនៅពេលនេះ ។ រង់ចាំរហូតដល់យើងបានបញ្ចប់ផែនការក្បត់របស់យើងសិន ។ ពេលនោះមិត្តម្នាក់ៗអាចយកប្រពន្ធ១០ ក៏បានដែរ ប្រសិនបើចង់បាន" ។ [...]
>
> វាគឺជាការប្រជុំនិយាយពីសកម្មភាពក្បត់ ពិព្រោះពួកនឹងធ្វើការបះបោរ ។ វាគឺជាការប្រជុំ CIA នៅពេលនោះពួកគេកំពុងធ្វើរៀបចំការប្រហារលើបន្ទាយ ប៉ុលពត តែបានបរាជ័យ ពិព្រោះ តាអឿន ដែលជាបក្សពួកតែមួយដូច ហ៊ុន សែន ត្រូវបានចាប់ខ្លួន[33] ។

២១. [redacted] (សាក្សី ង) មិនត្រូវបានចាប់ខ្លួនទេ ពិព្រោះគាត់ "មិនជាប់ទាក់ទងជាមួយការបះបោរ" "ពួកគេធ្វើតេស្តជំហររបស់ប្រជាជន នៅមុនពេលចាប់ខ្លួនពួកគេ"[34]។

### *vi) [redacted] (សាក្សី ច)*

---

[30] **E3/7583** "ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៣ ("ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា") ERN 00876549

[31] **E3/7583** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00876558

[32] **E3/7583** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00876558

[33] **E3/7583** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00876558-59

[34] **E3/7583** ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00876560

២២. [redacted] (សាក្សី ច) ជាទ័ពនៅក្នុងកងពលលេខ៣១0 ដែលមាន អឿន[35] ជាមេបញ្ជាការ ។ នៅដំណាច់ឆ្នាំ១៩៧៥ [redacted] (សាក្សី ច) ស្នើសុំឱ្យគេបញ្ជូនត្រឡប់ទៅមូលដ្ឋានវិញ[36]។ ក្រោយមកគាត់ត្រូវបានគេឃុំខ្លួនរយៈពេលបីខែនៅភូមិជីវិតភាព ស្រុកបារាយណ៍ ខេត្តកំពង់ធំ ហើយត្រូវបានសួរចម្លើយអំពី "ចលនាប្រឆាំងនៅខេត្តសៀមរាប ដែលគេស្គាល់ថាជាចលនាខ្មែរស ឬ ចលនាខ្មែរខៀវ"[37] ។ នៅគ្រាមួយនោះគាត់បានឃើញទ័ពនៅក្នុងអង្គភាពរបស់គាត់ "ត្រូវបានបញ្ជូនទៅកម្ទេចចលនាខ្មែរសនេះ"[38]។ នៅពេលសួរថាតើ កែ ពក និយមសហរដ្ឋអាមេរិក [redacted] (សាក្សី ច) និយាយថា:

> ខ្ញុំមិនជឿថា កែ ពក មានទំនាក់ទំនងជាមួយអាមេរិកាំងទេ ពិព្រោះគាត់ជាជនកុម្មុយនីស្តរ៉ាឌីកាល់ ។ ខ្ញុំអាចជឿថា អឿន មានទំនាក់ទំនងជាមួយអាមេរិកាំង ពិព្រោះគាត់ជាអតីតអនុសេនីយឯកក្នុងរបបចាស់ ដូច ទួន ចៃ ដែរ[39] ។

២៣. ផ្អែកលើកំណត់ហេតុនៃការសម្ភាន់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចដែលបានសង្ខេបខាងលើ ភស្តុតាងដែលរំពឹងទុកដែលសាក្សីប្រាំមួយនាក់អាចផ្តល់ គឺអាចជឿទុកចិត្ត និងពាក់ព័ន្ធ *ជាបឋម* ។ ជាទូទៅវាមិនត្រឹមតែពាក់ព័ន្ធនឹង "ការបោសសំអាតផ្ទៃក្នុង" តែក៏ពាក់ព័ន្ធមន្ទីរសន្តិសុខស២១ ដែរ ពិព្រោះភស្តុតាងនៅក្នុងកំណត់ហេតុបង្ហាញក្នុងចំណោមបញ្ហាផ្សេងទៀតថា អឿន កុយ ធួន និង ហូ នឹម-បើតាមសាក្សីប្រាំមួយនាក់ ជាប់ទាក់ទងជាមួយការប៉ុនប៉ងធ្វើរដ្ឋប្រហារ នឹងត្រូវបានសួរចម្លើយនៅមន្ទីរស២១[40]។ ភស្តុតាងដែលរំពឹងទុក ក៏ពាក់ព័ន្ធទៅនឹងចំណុចស្នូលនៃសំណុំរឿងរបស់ នួន ជា ដែរ និងជាពិសេសការអះអាងដែលថាថ្នាក់ដឹកនាំ

---

[35] **E3/2073 7583** "ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី២៤ ខែមករា ឆ្នាំ ២00៣ ("ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា") ERN 00876391, 00876394, 00876396

[36] ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា 00876400

[37] ការសម្ភាសន៍ [redacted] មជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00876415-18

[38] ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00876426-27

[39] ការសម្ភាសន៍ [redacted] ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00876433

[40] សូមមើលឧទាហរណ៍ **E3/1891** ចម្លើយរបស់ ស្បាយ ហ៊ីម ហៅ អឿន កងពលធំ៣១0 ("ចម្លើយសារភាពរបស់អឿន") ។ **E3/2791** ចម្លើយរបស់ចន្ទចន្ទ្រី ហៅ មាន កងពល១៧0 ("ចម្លើយសារភាពចន្ទចន្ទ្រី") ។ **E3/3856** ចម្លើយរបស់ កុយ ធួន ហៅ ធួន រដ្ឋមន្ត្រីពាណិជ្ជកម្ម" ។ **E3/1550** ចម្លើយរបស់ ហូ នឹម ហៅ ភាស់ រដ្ឋមន្ត្រីឃោសនាការ ។

កម្ពុជាប្រជាធិបតេយ្យ ត្រូវបានបែកខ្ញែកជាបក្សពួកទំនាស់ ដែលមួយចំនួនគាំទ្រជាសម្ងាត់ដោយវៀតណាម ។

២៤. ដោយសារមេធាវីការពារក្ដីរកបានកំណត់ហេតុនៃការសម្ភាន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសាក្សីប្រាំមួយនាក់នេះតាមរយៈ electronic interface នៅមុនចាប់ផ្ដើមការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ មេធាវីការពារក្ដីយល់ឃើញថា សំណើនេះដាក់ទាន់ពេលវេលា ។ ដោយគិតដល់តថភាពដែលគួរឱ្យស្ដាយថា វាមិនអាចទៅរួចបានទេដើម្បីកោះហៅសាក្សីទាំងអស់ដែលកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយរបស់ពួកគេ អាចរកបានដោយភាគី មេធាវីការពារព្យាយាមទាញយកភស្តុតាងពី កែវ លួរ និង សែម ហឿន ដែលអាចផ្ដល់ពន្លឺចំពោះព័ត៌មានលំអិតដែលគេមិនដឹង ដែលត្រូវបានបង្ហាញតិចតួចបំផុតនៅក្នុងការសម្ភាសន៍សាក្សីប្រាំមួយរូបដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ប៉ុន្តែវារំលេចឱ្យឃើញថា កែវ លួរ និង សែម ហឿន អាចមានព័ត៌មានកម្រិតដោយសារចំណែកជាក់លាក់របស់ពួកគេនៅក្នុងការបះបោរ និងការប៉ុនប៉ងធ្វើរដ្ឋប្រហារ[41]។ ជាលទ្ធផលសេចក្ដីត្រូវការស្ដាប់សក្ខីកម្មសាក្សីប្រាំមួយនាក់នេះកាន់តែដាច់ខាត និងជាក់ស្ដែង បន្ទាប់ពីការបញ្ចប់ការស្ដាប់សក្ខីកម្មរបស់ កែវ លឿ និង សែម ហឿន។ មេធាវីការពារក្ដីបានជូនដំណឹងអង្គជំនុំជម្រះ និង ភាគីរួចហើយពីគោលបំណងខ្លួនក្នុងការស្ដាប់សក្ខីកម្មសាក្សីច្រើននាក់ទៀត ទាក់ទងនឹងការបះបោរ និងការប៉ុនប៉ងធ្វើរដ្ឋប្រហារក្នុងអំឡុងពេលវគ្គសវនាការទាក់ទងនឹងការបោសសំអាតផ្ទៃក្នុងភ្លាមៗបន្ទាប់ពីការស្ដាប់សក្ខីកម្មរបស់សែម ហឿន[42]។ ដូច្នេះមេធាវីការពារក្ដីយល់ឃើញថា សំណើនេះដាក់ទាន់ពេលវេលា ។

២៥. ម្យ៉ាងទៀតសាក្សីនិមួយៗក្នុងចំណោមសាក្សីប្រាំមួយនាក់នេះ អាចផ្ដល់ព័ត៌មានល្អប្រសើរដែលទំនងជាមិនអាចទទួលបានពីសាក្សីដទៃទៀត ។ ឧទាហរណ៍សាក្សី [redacted] (សាក្សី ក) អាចផ្ដល់ភស្តុតាងទាក់ទងនឹងការជាប់ទាក់ទងរបស់ចាន់ចក្រី និង វៀតណាមនៅក្នុងការ

---

[41] សូមមើលឧទាហរណ៍ប្រតិចារិតសវនាការថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០១៥ (កែវ លួរ **E1/316.1** នៅទំព័រ ៧៨-៧៩ ។ ប្រតិចារិតសវនាការថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១៥ (សែម ហឿន **E1/319.1**) នៅទំព័រ៨២ ។ ប្រតិចារិតសវនាការថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១៥ (សែម ហឿន **E1/320.1** នៅទំព័រ ១០ ។

[42] សូមមើលកថាខណ្ឌ៣ខាងលើ ។

ប៉ុនប៉ងធ្វើរដ្ឋប្រហារ ។ សាក្សី [redacted] (សាក្សីខ) អាចផ្តល់ភស្តុតាងទាក់ទងនឹងការជាប់ទាក់ទងរបស់ កុយ ធួន ហ្វូ នឹម និង ហ្វូ យ៉ួន នៅក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារ និងការទំនាក់ទំនងរបស់ពួកគេ ។ សាក្សី [redacted] (សាក្សី ឃ) អាចផ្តល់ភស្តុតាងទាក់ទងនឹងតួនាទីរបស់ កុយ ធួន នៅក្នុងការបះបោរ ។ សាក្សី [redacted] (សាក្សី គ) អាចផ្តល់ភស្តុតាងទាក់ទងនឹងឯកសារសម្ងាត់ដែលបង្ហាញពីផែនការរដ្ឋប្រហារ និងការជាប់ទាក់ទងរបស់ សុខ និង សោភឹម នៅក្នុងរដ្ឋប្រហារ ។ សាក្សី [redacted] (សាក្សីង) អាចផ្តល់សក្ខីកម្មទាក់ ទងនឹងការប្រជុំសម្ងាត់ធ្វើឡើងដោយមេបញ្ជាការកងវរសេនាធំរបស់គាត់ និងការទំនាក់ទំនង រវាង អឿន និង ហ៊ុន សែន ហើយសាក្សី [redacted] (សាក្សី ច) អាចផ្តល់ភស្តុតាងទាក់ទង នឹងជម្លោះរវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យ និង ចលនាខ្មែរប្រឆាំងខ្មែរស ។ ភស្តុតាងដែល រំពឹងទុកដែលអាចផ្តល់ដោយសាក្សីទាំងនេះ គឺមានប្រយោជន៍ដល់ការបញ្ជាក់ការពិត និងសំខាន់ដល់ការពារក្តី ។ វាជាផលប្រយោជន៍យុត្តិធម៌ដើម្បីស្តាប់សក្ខីកម្មពួកគេដោយផ្ទាល់ ។

## ខ. ការស៊ើបសួរបន្ថែម

២៦. បន្ថែមពីលើសាក្សីដែលត្រូវបានសម្គាល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកចុះចូលដែលរត់ចេញពីកម្ពុជាក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ក៏បានផ្តល់ព័ត៌មានទាក់ទងនឹងការប៉ុនប៉ងធ្វើរដ្ឋប្រហារ ដែលដឹកនាំក្រុមប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យដែរ ។

### *i) ការប្រជុំសម្ងាត់នៅមុនការទម្លាក់គ្រាប់បែកនៅក្រុងសៀមរាប*

២៧. លោក Ben Kiernan បានលើកឡើងនៅក្នុងសៀវភៅរបស់គាត់ *The Pol Pot Regime* ថា "មេបញ្ជាការកងអនុសេនាធំដែលចុះចូលថៃនៅក្នុងឆ្នាំ១៩៧៧" បង្ហាញឲ្យដឹងពី "ការប្រជុំសម្ងាត់" ដែលរៀបចំឡើងដោយលេខាតំបន់១០៦ ឈ្មោះ ប៉ាចុល ហៅសុទ្ធ មួយថ្ងៃនៅមុនឧប្បត្តិហេតុទម្លាក់គ្រាប់បែកនៅទីក្រុងសៀមរាបក្នុងខែកុម្ភៈ ១៩៧៦[43]។ នាយទាហានដែលចុះចូលនេះបានអះអាងថា នៅកិច្ចប្រជុំនេះ៖

[43] **E3/1593**, B. Kiernan, *របបប៉ុល ពត: ពូជសាសន៍, អំណាច និង ប្រល័យពូជសាសន៍នៅកម្ពុជានៅក្រោមខ្មែរក្រហម ឆ្នាំ១៩៧៥-៧៩ នៅទំព័រ ៣១៧* ERN 01150165 (*The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rouge, 1975-79 (Yale University: 1996)* (Pol Pot Regime), corrected

កងទ័ពទាំងអស់នៅក្នុង [តំបន់] ១០៦ ចង់បង្កើតខុទ្ទាមកម្មមួយដែលអនុញ្ញាតឲ្យប្រជាជនវិលត្រឡប់ និងធ្វើការដូចដែលពួកបាននៅ និងធ្វើការនៅមុនការចាប់ទីក្រុងភ្នំពេញ...។ គឺត្រូវចាប់ផ្តើមនូវបដិវត្តថ្មី និងណែនាំមកវិញនូវទំលាប់អនុវត្តល្អនៃរបបចាស់[44] ។

២៨. អនុលោមតាម Kiernan អ្នកចុះចូលនេះក៏បាននិយាយថា អ្នកសមគំនិតជាច្រើននៅក្នុងកិច្ចប្រជុំនេះបាន "បានកំណត់ផ្លូវរត់ទៅថៃ ក្នុងករណីកំលាំងខុទ្ទាមរបស់ពួកគេត្រូវឡោមព័ទ្ធ"[45]។

## *ii) ការប៉ុនប៉ងធ្វើរដ្ឋប្រហារនៅដើមឆ្នាំ១៩៧៧*

២៩. លោក Kiernan ក៏បានបង្ហាញឲ្យដឹងនៅក្នុងសៀវភៅរបស់គាត់ថា ផ្អែកលើរឿងរ៉ាវរបស់អ្នកចុះចូលម្នាក់ដែលជាកងទ័ព ប.ក.ក ដែលទៅដល់ថៃនៅដំណាច់ឆ្នាំ១៩៧៧" កុយ ធួន ព្រមជាមួយលេខាតំបន់ ១០៦ សុទ្ធ មានផែនការធ្វើរដ្ឋប្រហារមួយទៀតនៅឆ្នាំ១៩៧៦[46]។ អនុលោមតាមអ្នកចុះចូលនេះ៖

នៅកិច្ចប្រជុំមួយនាខែកញ្ញា ឆ្នាំ១៩៧៦ នៅខេត្តឧត្តរមានជ័យ ភាគខាងជើងសៀមរាប ធួន និង សុទ្ធ មានផែនការធ្វើរដ្ឋប្រហារនៅទីក្រុងភ្នំពេញនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ។ ស្ថានីយវិទ្យុមួយត្រូវបានបង្កើតនៅខេត្តឧត្តរមានជ័យ ដើម្បីផ្សព្វផ្សាយការអំពាវនាវឲ្យធ្វើការបះបោរទូទៅ[47] ។

៣០. រដ្ឋប្រហារដែលនឹងកើតឡើងនៅដើមឆ្នាំ១៩៧៧ អាចជារដ្ឋប្រហារតែមួយដែល អឿន ដែលធ្លាប់ជាជននៅក្នុងឧបត្ថម្ភ (protégé) របស់ កុយ ធួន ត្រូវបានចោទប្រកាន់ជាប់ទាក់ទង ។ Kiernan ហាក់ដូចជាគិតថា រឿងរ៉ាងរបស់អ្នកចុះចូលនេះអាចសមហេតុផល ពិព្រោះប្រភពផ្សេងទៀតក៏ចង្អុលបង្ហាញថា កុយ ធួន អាចបានរត់ពីការឃុំខ្លួនក្នុងផ្ទះក្នុងមួយរយៈពេលខ្លីនៅឆ្នាំ១៩៧៦ នៅមុនចាប់ខ្លួនជាថ្មី និងបញ្ជូនមកស២១ នាខែមករា ឆ្នាំ១៩៧៧[48] ។

## *iii) ចាន់ ចក្រី ប៉ុនប៉ងធ្វើរដ្ឋប្រហារនៅឆ្នាំ១៩៧៦*

---

44 **E3/1593**, Pol Pot Regime, corrected, p. 317, ERN 01150165
45 **E3/1593**, Pol Pot Regime, corrected, p. 318, ERN 01150167
46 **E3/1593**, Pol Pot Regime, corrected, p. 340, ERN 01150177
47 **E3/1593**, Pol Pot Regime, corrected, p. 340, ERN 01150177 ។
48 **E3/1593** Pol Pot Regime, corrected, p. 317, ERN 01150169 ជាពិសេសជើងទំព័រលេខ៧០ ។

៣១. Kiernan ក៏បានយោងរឿងរ៉ាវរបស់អ្នកចុះចូលផ្សេងទៀតដែលបង្ហាញឲ្យដឹងពីការជាប់ទាក់ទងរបស់ចាន់ចក្រីនៅក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារៈ

> រំលឹកឡើងវិញដោយអតីតកងទ័ពម្នាក់ពីភូមិភាគបូព៌ាដែលឈរជើងនៅភ្នំពេញ "នៅរង្វង់ខែមេសា ឆ្នាំ១៩៧៦ កាំភ្លើងធំត្រូវបានដំឡើងនៅច្បារអំពៅ [...]" គោលបំណងគឺផ្ចោងដាក់ទីស្នាក់ការរបស់ ប៉ុល ពត" កងទ័ពម្នាក់នេះបន្ត "ខ្ញុំស្គាល់កងទ័ពចំនួនដែលជាប់ទាក់ទងជាមួយផែនការនេះ...។ ពួកគេមិនដឹងបញ្ជាមកពីណាទេ ។ តែមជ្ឈឹមបានដឹងអំពីផែនការនេះហើយបានបង្រាបវានៅមុនគេអនុវត្ត"[49] ។

៣២. រឿងរ៉ាវពីការប៉ុនប៉ងធ្វើរដ្ឋប្រហារនេះ គឺផ្អែកតាមការសម្ភាសន៍របស់ Stephen Heder ជាមួយ [redacted] (អ្នកចុះចូល X) ដែលជាអតីតកងទ័ពតំបន់២១ ភូមិភាគបូព៌ា និងដែលបានឈរជើងនៅទីក្រុងភ្នំពេញពីខែឧសភា១៩៧៥[50]។

៣៣. ដោយបានយោងទៅលើប្រភពផ្សេងទៀត Kiernan បានបន្ថែមថា អ្នកចុះចូលម្នាក់នៅឆ្នាំ១៩៧៧ បានរាយការណ៍ពីការជាប់ទាក់ទងនៃទាហានចំនួន៦០០នាក់របស់ចាន់ចក្រីនៅក្នុង "សង្កុបកម្ម (ការបះបោរយោធាន)"[51]។

៣៤. ដោយសារភស្តុតាងដែលរំពឹងទុករបស់សាក្សីប្រាំមួយនាក់បន្ថែម ភស្តុតាងដែលអ្នកចុះចូលអាចផ្តល់ទាក់ទងនឹងការប៉ុនប៉ងធ្វើរដ្ឋប្រហារដោយ កុយ ធួន ចាន់ ចក្រី អឿន និងកម្មាភិបាលជាន់ខ្ពស់ដទៃទៀតរបស់ ប.ក.ក គឺជាទូទៅមិនត្រឹមតែពាក់ព័ន្ធ "ការបោសសំអាតផ្ទៃក្នុង"ទេ តែក៏ពាក់ព័ន្ធមន្ទីរសន្តិសុខ២១ដែរ ។ សំខាន់ជាងនេះទៀតវាពាក់ព័ន្ធចំណុចស្នូលនៃការការពារក្តីលោក នួន ជា ហើយជាពិសេសការអះអាងដែលថាថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យបានបែកខ្ញែកជាក្រុមជម្លោះ ដែលអាចប៉ះពាល់ដល់ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលចោទប្រកាន់ ។ ព័ត៌មានជាសក្ខានុពលរបស់ជនផ្តាច់ខ្លួនទាំងនេះគឺមិនងាយរកបាន ហើយមិនទំនងជាទទួលបានពីប្រភពផ្សេងទៀតឡើយ។

៣៥. វិធាន៩៣នៃវិធានផ្ទៃក្នុង ផ្តល់អំណាចឲ្យអង្គជំនុំជម្រះសាលាដំបូង"បង្គាប់ឲ្យធ្វើការស៊ើប សួរបន្ថែមគ្រប់ពេលវេលា" នៅពេលណាអង្គជំនុំជម្រះយល់ឃើញ "ចាំបាច់" (បញ្ជាក់បន្ថែម)[52]។

---

[49] **E3/1593**, Pol Pot Regime, corrected, [redacted]
[50] **E3/1593**, Pol Pot Regime, corrected[redacted]
[51] **E3/1593**, Pol Pot Regime, corrected, [redacted]

ការស៊ើបសួរព័ត៌មានដែលបង្ហាញឲ្យដឹងដោយអ្នកចុះចូលខាងលើ គឺចាំបាច់សម្រាប់គោលបំណងបញ្ជាក់ការពិត និងបញ្ចៀសភាពអយុត្តិធម៌ ។

## V. សំណូមពរ

៣៦. **អាស្រ័យហេតុនេះ** សម្រាប់មូលហេតុទាំងអស់ដែលបានបញ្ជាក់នៅទីនេះមេធាវីការពារក្ដីសូមស្នើអង្គជំនុំជម្រះសាលាដំបូងមេត្តា:

(ក) កោះហៅ [redacted] (សាក្សី ក) [redacted] (សាក្សី ខ) សែម អំ (សាក្សី គ) [redacted] (សាក្សី ឃ) [redacted] (សាក្សី ង) និង [redacted] (សាក្សី ច) ឲ្យមកផ្ដល់សក្ខីកម្មនៅក្នុងវគ្គសវនាការទាក់ទងនឹងមន្ទីរសន្តិសុខស២១ និង

(ខ) បង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមដើម្បីកំណត់អត្តសញ្ញាណ និងស្វែងរក i) អ្នកចុះចូលដែលថែងនៅកថាខណ្ឌ ២៧-៣៣ និង ii) កំណត់ហេតុដែលអាចរកបានទាំងឡាយនៃការសម្ភាសន៍អ្នកចុះចូលទាំងនេះ។

**សហមេធាវីការពារក្ដីលោក នួន ជា**

**សុន អរុណ** Victor KOPPE

[52] ផ្ទុយពីវិធាន ៨៧ វិធាន ៩៣ មិនបានកំណត់ពេលវេលាសម្រាប់ការស៊ើបអង្កេតបន្ថែមឡើយ។ ជាការពិតណាស់អង្គជំនុំជម្រះបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនតាមវិធាន ៩៣ នៅពេលចុងក្រោយក្នុងការដោះស្រាយ។ សូមមើល ដូចជាឯកសារ **E266/3** "សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាតាមវិធាន ៩៣ ពាក់ព័ន្ធនឹងសាក្សីសក្ខានុពល ណូ មុក ព្រមទាំងសំណើស្ដាប់សក្ខីកម្មរបស់សាក្សីរូបនេះ" ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ ២០១៣។